វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១០ ខែឧសភា ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- គណៈប្រតិភូកម្ពុជាចូលរួមដំណើរទស្សនកិច្ចទៅប្រទេសបារាំងក្រោមប្រធានបទហិរញ្ញប្បទានលើការអភិវឌ្ឍប្រកបដោយចីរភាព
- វៀតណាមអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីជំរុញការផលិតសម្លៀកបំពាក់ និងវាយនភ័ណ្ឌ
- ការវិនិយោគរបស់ចិននៅក្នុងអាជីវកម្មទើបចាប់ផ្តើមថ្មីៗនៅអាមេរិក អាចនឹងត្រូវធ្លាក់ចុះពីកម្រិតកំពូលនៅឆ្នាំ២០១៨

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### គណៈប្រតិភូកម្ពុជាចូលរួមដំណើរទស្សនកិច្ចទៅប្រទេសបារាំងក្រោមប្រធានបទ ហិរញ្ញប្បទានលើការអភិវឌ្ឍប្រកបដោយចីរភាព

កាលពីថ្ងៃ០៣ ឧសភា កន្លងទៅនេះឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំគណៈប្រតិភូមួយក្រុមទៅកាន់ទៅក្រុងប៉ារីស ដើម្បីចូលរួមកិច្ចប្រជុំកំពូលមួយស្តីពី "ចីរភាពបំណុលសម្រាប់ចីរភាពកំណើន៖ ចីរភាពហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ" នេះបើយោងតាមសេចក្តីប្រកាសពត៌មានរបស់ក្រសួង។ រដ្ឋមន្ត្រី និងមន្ត្រីកម្ពុជាមួយចំនួនត្រូវបានអញ្ជើញដោយក្រសួងហិរញ្ញវត្ថុរបស់បារាំង។ អ្នកចូលរួមផ្សេងទៀត រួមមាន រដ្ឋមន្ត្រីហិរញ្ញវត្ថុ ទេសាភិបាលធនាគារកណ្តាល ប្រធានស្ថាប័នអន្តរជាតិ ស្ថាប័នសិក្សាស្រាវជ្រាវ និងតំណាងពីស្ថាប័នហិរញ្ញវត្ថុធំៗ មកពីតាមបណ្តាប្រទេសប្រមាណ៦០ នៅលើពិភពលោក។

គណៈប្រតិភូបានពិភាក្សាយុទ្ធសាស្ត្រហិរញ្ញប្បទានដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ហិរញ្ញប្បទានសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងយុទ្ធសាស្ត្រដើម្បីជៀសវាងនូវការជំពាក់បំណុលច្រើនហួសហេតុ។

គណៈប្រតិភូកម្ពុជា ក៏បានជួបពិភាក្សាការងារទ្វេភាគីជាមួយតំណាងជាន់ខ្ពស់នៃក្រសួងហិរញ្ញវត្ថុបារាំង សហគមន៍អឺរ៉ុប និងអង្គការអភិវឌ្ឍន៍នានាផងដែរ។ ក្នុងចំនោមដៃគូទាំងនោះ កម្ពុជារំពឹងថានឹងចុះហត្ថលេខាមួយលើ កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គម្រោងធ្វើទំនើបកម្មលើប្រព័ន្ធបណ្តាញបញ្ជូន និងចែកចាយអគ្គិសនី ក្នុងទឹកប្រាក់ចំនួន ២៩,១ លានអឺរ៉ូ។

### តារាងប្រចាំសប្តាហ៍៖ ចំណូលថវិកាត្រីមាសដំបូង

តារាងប្រចាំសប្តាហ៍នេះបង្ហាញអំពី ចំណូលក្នុងស្រុក ពីខែមករាដល់ខែមីនា ឆ្នាំ២០១៩ ធៀបនឹងឆ្នាំ២០១៨។ ចំណូលបានកើនឡើងដល់ ២,០០៥ ប៊ីលានរៀលនៅក្នុងខែមីនា ពោលគឺមានការ

កើនឡើង១២% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ។ ជាសរុប ចំណូលនៅក្នុងត្រីមាសទី១ នៃឆ្នាំ ២០១៩ បានកើនឡើង ១៣,១% បើធៀបទៅនឹងត្រីមាសទីមួយនៃឆ្នាំ២០១៨ ។

**ចំណូលក្នុងស្រុកសរុប (គិតជាប៊ីលានរៀល) ត្រីមាសទី១ ឆ្នាំ២០១៩**




ប្រភព៖ ទិន្នន័យបឋមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### វៀតណាមអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីជំរុញការផលិតសម្លៀកបំពាក់ និងវាយនភ័ណ្ឌ

យោងតាមមជ្ឈមណ្ឌលលើកកម្ពស់ការវិនិយោគ និងពាណិជ្ជកម្មទីក្រុងហូជីមិញបានឱ្យដឹងថា ប្រទេសវៀតណាមកំពុងអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី(FTA) ដើម្បីពង្រីកចំណែកទីផ្សារនៅក្នុងវិស័យកាត់ដេរ និងវាយនភ័ណ្ឌរបស់ខ្លួននៅលើសកលលោក ដើម្បីក្លាយជា«អ្នកផលិតម៉ាកល្បីៗ នៅលើពិភពលោក»។ ដូចដែលបានរាយការណ៍ដោយ កាសែតភ្នំពេញប៉ុស្តិ៍។

កិច្ចព្រមព្រៀងពាណិជ្ជកម្មរួមមាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពអឺរ៉ុប-វៀតណាម និងកិច្ចព្រមព្រៀងទូលំទូលាយ និងរីកចម្រើនទៅមុខនៃភាពជាដៃគូឆ្លងមហាសមុទ្រប៉ាស៊ីហ្វិក (CPTPP) កំពុងទទួលអត្ថប្រយោជន៍ពីតម្លៃពលកម្មមានលក្ខណៈប្រកួតប្រជែង និងគោលនយោបាយពាណិជ្ជកម្មអនុគ្រោះរបស់វៀតណាម ដើម្បីបង្កើនការបញ្ជាទិញផលិតផលសម្លៀកបំពាក់ និងវាយនភណ្ឌ។

មកដល់ពេលនេះ ក្រុមហ៊ុនបរទេសបានវិនិយោគប្រហែល ១៧,៥ ប៊ីលានដុល្លារក្នុងឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌវៀតណាម។ ក្នុងឆ្នាំ២០១៨ ឧស្សាហកម្មនេះ រកចំណូលបាន ៣៦ ប៊ីលានដុល្លារពីការនាំចេញ ដែលធ្វើឱ្យប្រទេសវៀតណាមក្លាយជាអ្នកនាំចេញវាយនភណ្ឌធំមួយ ក្នុងចំណោមអ្នកនាំចេញធំជាងគេរបស់ពិភពលោក។ នៅឆ្នាំ២០១៩ គេរំពឹងថាឧស្សាហកម្មនេះ នឹងនាំមកនូវទឹកប្រាក់ចំនួន ៤០ប៊ីលានដុល្លារពីការនាំចេញ ដែលជាកំណើន ១១% ហើយបានកំណត់គោលដៅនាំចេញប្រមាណ ៦០ប៊ីលានដុល្លារសម្រាប់ឆ្នាំ ២០២៥។

## សេដ្ឋកិច្ចពិភពលោក

### ការវិនិយោគរបស់ចិននៅក្នុងអាជីវកម្មទើបចាប់ផ្ដើមថ្មីៗនៅអាមេរិក អាចនឹងត្រូវធ្លាក់ចុះពីកម្រិតកំពូលនៅឆ្នាំ២០១៨

យោងតាមការរាយការណ៍របស់សារព័ត៌មានReuter ក្រុមហ៊ុនរបស់ចិនបានវិនិយោគទឹកប្រាក់ចំនួន ៣,៦ ប៊ីលានដុល្លារនៅក្នុងអាជីវកម្មទើបចាប់ផ្ដើមថ្មីៗនៅសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៨ ប៉ុន្តែមានលក្ខខណ្ឌចំរូងចម្រាស់កាន់តែខ្លាំងឡើង ដែលត្រូវបានគេគិតថានឹងជាមូលហេតុធ្វើអោយមូលនិធិចិនធ្លាក់ចុះក្នុងឆ្នាំនេះ បើយោងទៅតាមរបាយការណ៍ថ្មីដោយក្រុមហ៊ុនស្រាវជ្រាវសេដ្ឋកិច្ច Rhodium Group ។

ច្បាប់ថ្មីមួយរបស់អាមេរិក ដែលមានឈ្មោះថាFIRRMA បានពង្រីកអំណាចរបស់គណៈកម្មាធិការពិសេស ដែលស៊ើបអង្កេតលើប្រតិបត្តិការរបស់ជនបរទេសដើម្បីទិញភាគហ៊ុនភាគតិចនៅក្នុងអាជីវកម្មទើបចាប់ផ្ដើមដំបូងនៅអាមេរិក។ ច្បាប់និងភាពមិនច្បាស់លាស់របស់ច្បាប់ថ្មីនេះ គឺត្រូវបានគេគិតថានឹងជះឥទ្ធិពលមិនល្អទៅលើការវិនិយោគ។ ក្រុមហ៊ុនRhodium បានសង្កេតឃើញថា ការវិនិយោគពីវិនិយោគិនដែលជារដ្ឋចិន បានបាត់ទៅវិញស្ទើរទាំងអស់ក្នុងអំឡុងខែកុម្ភៈឆ្នាំ២០១៩។

រដ្ឋាភិបាលចិន និងអ្នកវិនិយោគមូលធនចិន បានចាប់ផ្ដើមជៀសវាងការចាប់ផ្ដើមអាជីវកម្មដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យា ដោយព្រួយបារម្ភថាកិច្ចព្រមព្រៀងទាំងឡាយអាចនឹងត្រូវបានបដិសេធ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ព្រឹត្តិការណ៍សប្តាហ៍បន្ទាប់រួមមាន ការបោះឆ្នោតជាសកលនៅហ្វីលីពីន និងការសម្រេចអត្រាការប្រាក់នៅក្នុង ឥណ្ឌូនេស៊ី។

ខាងក្រោមនេះ គឺជាប្រតិទិនពេញលេញនៃការចេញផ្សាយទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុមការងារ FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ។

ថ្ងៃចន្ទ ទី១៣ ខែឧសភា

- ការបោះឆ្នោតសកល នៅហ្វីលីពីន
- ការវិនិយោគផ្ទាល់ពីបរទេស នៅចិន សម្រាប់ខែមេសា
- ការលក់រាយនៅ ម៉ាឡេស៊ី សម្រាប់ខែមីនា
- ការលក់រថយន្តនៅចិន សម្រាប់ខែមេសា

ថ្ងៃអង្គារ ទី១៤ ខែឧសភា

- ការលក់ម៉ូតូនៅឥណ្ឌូណេស៊ី សម្រាប់ខែមេសា
- អត្រាគ្មានការងារធ្វើរបស់កូរ៉េខាងត្បូង សម្រាប់ខែមេសា
- ផលិតកម្មឧស្សាហកម្មតំបន់ដែលប្រើប្រាស់រូបិយបណ្ណអឺរ៉ូ សម្រាប់ខែមីនា

ថ្ងៃពុធ ទី១៥ ខែឧសភា

- ផលិតកម្មឧស្សាហកម្មចិន សម្រាប់ខែមេសា
- ការលក់រាយនៅ ចិន សម្រាប់ខែមេសា
- តុល្យភាពពាណិជ្ជកម្មឥណ្ឌូណេស៊ី សម្រាប់ខែមេសា
- ផសស របស់តំបន់ដែលប្រើប្រាស់រូបិយបណ្ណអឺរ៉ូ សម្រាប់ឆ្នាំ២០១៩
- ផលិតកម្មឧស្សាហកម្មអាមេរិក សម្រាប់ខែមេសា

ថ្ងៃព្រហស្បតិ៍ ទី១៦ ខែឧសភា

- ផសសរបស់ម៉ាឡេស៊ី សម្រាប់ឆ្នាំ ២០១៩
- ការសម្រេចអត្រាការប្រាក់ឥណ្ឌូណេស៊ី
- តុល្យភាពពាណិជ្ជកម្មនៃតំបន់ដែលប្រើប្រាស់រូបិយបណ្ណអឺរ៉ូ សម្រាប់ខែមីនា

ថ្ងៃសុក្រ ទី១៧ ខែឧសភា

- តុល្យភាពពាណិជ្ជកម្មនៅសឹង្ហបុរី សម្រាប់ខែមេសា
- កំណើនផសស នៅហុងកុងសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- អតិផរណាតំបន់ដែលប្រើប្រាស់រូបិយបណ្ណអឺរ៉ូ សម្រាប់ខែមេសា
- ការលក់រថយន្តនៅឥណ្ឌូនេស៊ី សម្រាប់ខែមេសា